# Play YOUR WAY

## កម្មវិធីតាមដានការលេងល្បែង ស៊ីសងផ្ទាល់ខ្លួនដោយឥតគិតថ្លៃរបស់អ្នក។

Your Play
Play your way

# តើ YourPlay ជាអ្វី?

## តាមដានលុយ និងពេលវេលាដែលបានចំណាយ

YourPlay ផ្តល់ឲ្យអ្នកនូវសិទ្ធិដើម្បីតាមដាន ថាតើអ្នកកំពុងចំណាយលុយ និងពេលវេលាប៉ុន្មាន នៅពេលអ្នកកំពុងលេង។ អេក្រង់នៅម៉ាស៊ីនលេងល្បែងស៊ីសងរបស់អ្នក បង្ហាញប្រាប់ពីចំនួនសរុប ដើម្បីឲ្យអ្នកបានដឹងជានិច្ចអំពីស្ថានភាពលេងរបស់អ្នក។ អ្នកអាចបិទ ឬបើកអេក្រង់នៅពេលណាក៏បាន ដើម្បីការពារភាពឯកជនរបស់អ្នក។

## រៀបចំកម្រិតលេង និងពាក្យរំលឹក

ដើម្បីទទួលបានផលប្រយោជន៍ពេញលេញនៃ YourPlay អ្នកអាចជ្រើសដើម្បីដាក់កម្រិតប្រាក់ ឬពេលម៉ោងដែលអ្នកចំណាយ - ឬទាំងពីរ។ ការបង្ហាញនឹងផ្តល់ឲ្យអ្នកនូវការរំលឹកមួយ ពេលណាអ្នកលេងដល់៧០ភាគរយ និង៩០ភាគរយនៃកម្រិតលេងរបស់អ្នក។ អ្នកថែមទាំងអាចសរសេរសារ រំ លឹកផ្ទាល់ខ្លួនរបស់អ្នកដែរ ជាការលើកទឹកចិត្តដើម្បីឲ្យអ្នកប្រកាន់ខ្ជាប់ទៅនឹងកម្រិតលេងរបស់អ្នក។

## ពិនិត្យមើលប្រវត្តិលេងរបស់អ្នក

អ្នកប្រើប្រាស់ YourPlay នឹងទទួលបាន សេចក្តីប្រកាសប្រចាំឆ្នាំ។ ដើម្បីឲ្យអ្នកអាចមើលឃើញសកម្មភាពលេងរបស់ អ្នកក្នុងអំឡុងពេលលេងណាមួយ ក្នុងមួយសប្តាហ៍ មួយខែឬមួយឆ្នាំ។ អ្នកទទួលបានសេចក្តីប្រកាសតាមអនឡាញ តាមអ៊ីម៉េល ឬរៀបចំឲ្យគេផ្ញើទៅអាសយដ្ឋានផ្ទះរបស់អ្នក។






ពិនិត្យមើលការបង្ហាញដើម្បីឲ្យ
ឃើញពីរបៀបដែលអ្នកកំពុងតាមដាន




រៀបចំកម្រិតលេងផ្ទាល់ខ្លួន
និងពាក្យរំលឹកផ្ទាល់ខ្លួនរបស់អ្នក




សេចក្តីប្រកាសផ្ទាល់ខ្លួនអនុញ្ញាតឲ្យ
អ្នកមើលឃើញសកម្មភាពលេងរបស់
អ្នកក្នុងអំឡុងពេលណាមួយ

# ជាមួយ YourPlay អ្នកអាច

> តាមដានលុយ និងពេលម៉ោងដែលអ្នកបានចំណាយ ខណៈដែលអ្នកកំពុងលេង

> ជ្រើសដើម្បីរៀបចំការកំណត់កម្រិតលេង និងពាក្យរំលឹកផ្ទាល់ខ្លួន

> ទទួលយកសេចក្តីប្រកាសអំពីសកម្មភាពលេងរបស់អ្នក

# តើខ្ញុំអាចចាប់ផ្ដើមប្រើប្រាស់ **YourPlay** ដោយបែបណា?




អ្នកអាចចុះបញ្ជីសម្រាប់ YourPlay
តាមអនឡាញ **yourplay.com.au**
ឬតាមរយៈតូបនៅកន្លែងលេងល្បែង
ស៊ីសងក្នុងតំបន់របស់អ្នក។ ប្រសិនបើអ្នកច
ង់តាមដានការលេងរបស់អ្នក
ដោយមិនចាំបាច់ចុះព័ត៌មានលម្អិតរប
ស់អ្នក សូមសួររកប័ណ្ណលេងម្ដងម្កាល
YourPlay នៅកន្លែងលេងល្បែងស៊ីសង។
ប្រសិនបើអ្នកត្រូវការជំនួយណាមួយ
សូមសួរសមាជិកបុគ្គលិក។




អ្នកអាចរៀបចំកម្រិតពេលម៉ោងលេង
និងការចំណាយលុយ ពេលណា
អ្នកចុះបញ្ជី។ ប្រសិនបើអ្នកត្រូវការពេល
ដើម្បីគិតអំពីរឿងនេះ អ្នកអាចរៀបចំការ
នេះបានជានិច្ចនៅពេលក្រោយ។ ប្រសិន
បើអ្នកគ្រាន់តែចង់តាមដានការលេងរបស់
អ្នកសូមគ្រាន់តែជ្រើសរើស "គ្មានកម្រិត"
ប៉ុណ្ណោះ។




អ្នកត្រូវការប័ណ្ណដើម្បីចូលដំណើរការ
YourPlay។ អ្នកអាច ទទួលយក
ប័ណ្ណរបស់អ្នក នៅកន្លែងលេង
ល្បែងស៊ីសងណាមួយក្នុងរដ្ឋវិចតូរីយ៉ា។
ស៊កប័ណ្ណរបស់អ្នកទៅក្នុងម៉ាស៊ីនអា
នប័ណ្ណ នៅម៉ាស៊ីនលេងល្បែងស៊ីសង
វាយបញ្ចូលលេខសម្ងាត់របស់អ្នក
ហើយអ្នកត្រៀមខ្លួនជាស្រេចដើម្បីលេង។

កុំភ្លេច អ្នកនឹងទទួលបានសេចក្ដីប្រកាសប្រចាំឆ្នាំមួយ ដែលបង្ហាញពីសកម្មភាពលេងរបស់អ្នក។ អ្នកក៏អាចមើលព័ត៌មានទាំងអស់របស់អ្នកផងដែរ នៅលើវិបសាយ **YourPlay** ឬនៅតូបកន្លែងលេង ល្បែងស៊ីសង។

## #1 លើ ដំបូន្មានសំខាន់

អ្នកនឹងត្រូវការបង្ហាញអត្តសញ្ញាណ (ឧទាហរណ៍ ប័ណ្ណបើកបរ វិក្កយបត្រសេវាសំខាន់ៗ) ដើម្បីទទួលយកប័ណ្ណ ដែលបានចុះបញ្ជីរបស់អ្នក។ ឈ្មោះដំបូង និងចុងក្រោយ នៅលើអត្តសញ្ញាណរបស់អ្នក ត្រូវតែដូចគ្នានឹងឈ្មោះ ដែលអ្នកបានប្រើដើម្បីចុះបញ្ជីសម្រាប់ **YourPlay**។

## #2 លើ ដំបូន្មានសំខាន់

រៀបចំ ឬផ្លាស់ប្ដូរកម្រិតលេងរបស់អ្នកនៅពេលណាក៏បាន។ ចូលទៅកាន់ **yourplay.com.au** ឬប្រើតូបកន្លែងលេងល្បែងស៊ីសង។

## #3 លើ ដំបូន្មានសំខាន់

សូមចងចាំលេខសម្ងាត់របស់អ្នក។ អ្នកនឹងត្រូវវាយបញ្ចូលវា ពេលណាអ្នកស៊ិកប័ណ្ណ របស់អ្នក នៅក្នុងម៉ាស៊ីនអានប័ណ្ណ។

## តើចង់ដឹងបន្ថែមទៀតឬ?

- បើកចូល **yourplay.com.au**
- និយាយទៅកាន់បុគ្គលិកនៅកន្លែងលេងល្បែងស៊ីសង
- ទូរស័ព្ទតុជំនួយ YourPlay លេខ **1300 838 031** ម៉ោង១០ព្រឹក ដល់ម៉ោង៦យប់ (AEST) ៧ថ្ងៃក្នុងមួយសប្ដាហ៍។
- អ៊ីម៉េល **support@yourplay.com.au**

# តើត្រូវការជំនួយបន្ថែមឬទេ?

### សូមសួរនៅកន្លែងលេងល្បែងស៊ីសង ក្នុងតំបន់របស់អ្នក

ច្បាប់ទូន្មាននៃការលេងល្បែងស៊ីសង នៅកន្លែងលេងល្បែងស៊ីសងដែលមានអាជ្ញាប័ណ្ណរបស់រដ្ឋវិចតូរីយ៉ា តម្រូវឲ្យបុគ្គលិកជួយអ្នកប្រើប្រាស់ YourPlay។ ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម ជួយក្នុងការចុះបញ្ជី ឬប្រតិបត្តិការតូប YourPlay សូមសួរសមាជិកបុគ្គលិកនៅកន្លែងលេងល្បែងស៊ីសង។

### លទ្ធភាពដើម្បីប្រើប្រាស់

សូមទាក់ទង Department of Justice & Regulation Strategic Communication Branch តាមទូរស័ព្ទលេខ 03 8684 0334 ឬអ៊ីម៉េល editor@justice.vic.gov.au ប្រសិនបើអ្នកត្រូវការព័ត៌មាននេះក្នុងសណ្ឋានដែលអាចបើកមើលបាន។

### តើមានកង្វល់អំពីកម្រិតលេងល្បែងស៊ីសងរបស់អ្នកឬ?

មានវិធីជាច្រើនដើម្បីទទួលបានការផ្គត់ផ្គង់។ Gambler's Help ផ្ដល់ជូនសេវា២៤ម៉ោង ជាសម្ងាត់ ហើយឥតគិតថ្លៃ។ សូមទូរស័ព្ទ Gambler's Help លេខ 1800 858 858។

### តើមានកង្វល់អំពីអាកប្បកិរិយានៃការលេងល្បែងស៊ីសងឬ?

ប្រសិនបើអ្នកមានកង្វល់ណាមួយ អំពីអាកប្បកិរិយានៃការលេងល្បែងស៊ីសងក្នុងរដ្ឋវិចតូរីយ៉ា សូមទាក់ទង Victorian Commission for Gambling and Liquor Regulation លេខ 1300 182 457។

# កិច្ចការពាររឿងឯកជនរបស់អ្នក

ពេលណាអ្នកចុះបញ្ជីជាមួយ YourPlay គ្រប់ព័ត៌មានរបស់អ្នកគឺសម្ងាត់ ហើយត្រូវបានការពារដោយច្បាប់ រួមមាន*ច្បាប់ការពាររឿងឯកជន និងទិន្នន័យ ឆ្នាំ 2014*។ សម្រាប់គោលនយោបាយរឿងឯកជនរបស់យើងខ្ញុំ សូមបើកចូលវ៉ិបសាយ yourplay.com.au

គម្រោងប្ដូរផ្ដាច់ជាមុន មានផ្ដល់នៅក្រោមអាជ្ញាបណ្ណប្រគល់ទៅឲ្យរដ្ឋវិចតូរីយ៉ា។
កូនសៀវភៅនេះបោះពុម្ពផ្សាយដោយ Department of Justice & Regulation
© រដ្ឋវិចតូរីយ៉ា។

# សំណួរអំពី YourPlay

## តើខ្ញុំទទួលបានប័ណ្ណនៅកន្លែងណា?

អ្នកអាចទទួលបានប័ណ្ណមួយ ដើម្បីចូលលេងនៅកន្លែងលេងល្បែងស៊ីសង YourPlay ណាមួយ រួមទាំងកាស៊ីណូក្រុងម៉េលប៊ិនផងដែរ។

## តើខ្ញុំអាចដាក់បន្ថែម YourPlay ទៅនឹងប័ណ្ណភាពស្មោះត្រង់បានឬទេ?

បាន។ ប្រសិនបើអ្នកមានប័ណ្ណភាពស្មោះត្រង់រួចហើយ សូមគ្រាន់តែស្នើសុំបុគ្គលិកនៅកន្លែងលេងល្បែងស៊ីសង ដើម្បីឲ្យគេដាក់បន្ថែម YourPlay ប៉ុណ្ណោះ។ ជានិច្ចជាកាល ព័ត៌មានគណនី YourPlay គឺជាព័ត៌មានឯកជនទាំងស្រុង ហើយដាច់ដោយឡែកពីទិន្នន័យផ្សេងទៀតណាមួយដែលរក្សាទុកនៅក្នុងប័ណ្ណ។

## តើខ្ញុំអាចមានប័ណ្ណច្រើន ជាមួយនឹង YourPlay បានឬទេ?

អ្នកអាចចូលដំណើរការ YourPlay តាមរយៈប័ណ្ណច្រើន តាមដែលអ្នកត្រូវការ។ ការចុះបញ្ជី YourPlay នឹងត្រូវតភ្ជាប់ទៅនឹងប័ណ្ណនីមួយៗ ដើម្បីឲ្យអ្នកអាចតាមដានការលេងរបស់អ្នក នៅកន្លែងលេងល្បែងស៊ីសងនីមួយៗ។

## តើមានអ្វីកើតឡើងប្រសិនបើខ្ញុំបាត់ប័ណ្ណរបស់ខ្ញុំ?

ប្រសិនបើអ្នកបានចុះបញ្ជី អ្នកអាចទទួលប័ណ្ណជំនួសមួយទៀត។ ប័ណ្ណលេងម្តងម្កាលមិនអាចដាក់ជំនួសបានឡើយ ដូច្នេះប្រសិនបើអ្នកបាត់ប័ណ្ណរបស់អ្នក អ្នកនឹងបាត់ប្រវត្តិនៃការលេងរបស់អ្នកដែរ។

## តើខ្ញុំអាចចុះបញ្ជីប័ណ្ណលេងម្តងម្កាលរបស់ខ្ញុំបានឬទេ?

បាន។ សូមគ្រាន់តែសួរបុគ្គលិកកន្លែងលេងល្បែងស៊ីសងប៉ុណ្ណោះ។ អ្នកនឹងត្រូវការបង្ហាញអត្តសញ្ញាណដើម្បីចុះបញ្ជី ប័ណ្ណ។ ការចុះបញ្ជីមានន័យថា អ្នកអាចរក្សាទុកប្រវត្តិនៃការលេងមកទល់នឹងបច្ចុប្បន្នភាព។

## តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំឈានដល់កម្រិតលេងណាមួយ?

ម៉ាស៊ីនល្បែងស៊ីសងនឹងឈប់ដំណើរការ ដើម្បីផ្តល់ឲ្យអ្នកនូវពេលវេលា ដើម្បីសម្រេចថាតើ អ្នកចង់បន្តការលេងទៀតឬអត់។ សូមចងចាំផងដែរ ប្រសិនបើអ្នកចង់ *បង្កើន* កម្រិតលេងរបស់អ្នក បន្ទាប់ពីអ្នកបានចាប់ផ្តើមលេង អ្នកនឹងត្រូវរង់ចាំយ៉ាងហោចណាស់២៤ម៉ោង ដើម្បីឲ្យកម្រិតលេងថ្មីរបស់អ្នកមានដំណើរការ។

## តើមានអ្វីកើតឡើងដល់ពិន្ទុភាពស្មោះត្រង់ ប្រសិនបើខ្ញុំបានដាក់កម្រិតលេងមួយ ហើយឈានទៅដល់កម្រិតលេងនោះ?

ប្រសិនបើអ្នកកំពុងប្រើប័ណ្ណភាពស្មោះត្រង់ ដោយដាក់បន្ថែម YourPlay ហើយអ្នកបានជ្រើសរើសដាក់កម្រិតលុយ និង/ឬម៉ោងលេង អ្នកនឹងឈប់ លែងបានទទួលពិន្ទុភាពស្មោះត្រង់ ពេលណាអ្នកឈានដល់កម្រិតលេងរបស់អ្នក។ ពិន្ទុទាំងនេះនឹងចាប់ផ្តើមជាថ្មីម្តងទៀត កាលណាអំឡុងពេលកម្រិតលេងថ្មីមួយបានចាប់ផ្តើម។

## តើខ្ញុំអាចដាក់បញ្ចូលលុយទៅក្នុងប័ណ្ណ YourPlay របស់ខ្ញុំបានឬទេ?

ទេ។ ប័ណ្ណ YourPlay របស់អ្នក មិនអាចរក្សាទុកឥណទានណាមួយទេ។ វាមាននៅទីនោះយ៉ាងប្រាកដច្បាស់ ដើម្បីផ្តល់ឲ្យអ្នកនូវសិទ្ធិតាមដានការលេងរបស់អ្នក និងដាក់កម្រិតលេងផ្ទាល់ខ្លួនរបស់អ្នក។

Play your way

ចុះបញ្ជីសម្រាប់ YourPlay នៅត្រង់ **yourplay.com.au**
នៅកន្លែងគិតលុយ ឬនៅតាមតូបកន្លែងលេងល្បែងស៊ីសងដែលមាន
អាជ្ញាបណ្ណក្នុងរដ្ឋវិចតូរីយ៉ា។

**សម្រាប់ព័ត៌មានបន្ថែម:**
ទូរស័ព្ទគុជំនួយ YourPlay លេខ **1300 838 031**
ម៉ោង១០ព្រឹក ដល់ម៉ោង ៦យប់ (AEST) ៧ថ្ងៃក្នុងមួយសប្តាហ៍។

## yourplay.com.au

YourPlay បានគាំទ្រដោយរដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា
តាមរយៈមូលនិធិផ្គត់ផ្គង់សហគមន៍។